ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
អគ្គលេខាធិការដ្ឋាន
លេខ : ១២១/០៨ របក/អ.ញ.ប.គ.ញ

រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ២០០៨

# របាយការណ៍
## ស្តីពី
## លទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០០៨

របស់អគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

(១១/១២/២០០៧-៣០/១១/២០០៨)

ឆ្នាំ២០០៨នេះ អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តយកចិត្តទុកដាក់សហការ សម្របសម្រួល ជាមួយក្រសួង-ស្ថាប័នរដ្ឋាភិបាល អង្គការជាតិ អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាលដែលពាក់ព័ន្ធអនុវត្តនូវ **គោលនយោបាយ** និង **យុទ្ធសាស្ត្រ** ក្នុងការត្រួតពិនិត្យគ្រឿងញៀនសំដៅ ទប់ស្កាត់ និង កាត់បន្ថយ នូវគ្រោះថ្នាក់ដែលបណ្តាលមកពីបញ្ហាគ្រឿងញៀន ។

**ជាមួយនោះ** អង្គភាពអនុវត្តន៍ច្បាប់បានបន្តយកចិត្តទុកដាក់លើកិច្ចប្រតិបត្តិការបង្ក្រាបបទល្មើសគ្រឿងញៀនយ៉ាងសកម្ម ដើម្បីរួមចំណែកក្នុងការរក្សា សន្តិសុខ សុវត្ថិភាព និង សណ្តាប់ធ្នាប់សង្គម ។ តាមរយៈកិច្ចប្រតិបត្តិការបង្ក្រាបបទល្មើស យើងក្តាប់បានសភាពការណ៍គ្រឿងញៀនដូចតទៅ :

## I / សភាពការណ៍គ្រឿងញៀន :

### ១-ការផលិត

### ១.១-គ្រឿងញៀនសំយោគ ATS

ឆ្នាំ២០០៨នេះ ការផលិតក្លែងក្លាយនិងកែច្នៃគុណភាពនូវគ្រឿងញៀនសំយោគATS បានបន្តលបលួចផលិតដើម្បីផ្គត់ផ្គង់ការប្រើប្រាស់ ។ ការផលិតធ្វើឡើងដោយពុម្ពកែច្នៃដែលត្រូវបានរកឃើញចំនួន២លើកនៅរាជធានីភ្នំពេញ ។ តាមរយៈការបង្ក្រាបករណីទាំងពីរនេះបានកត់សំគាល់ឃើញថាគ្រាប់មេតំហ្វេតាមីនត្រូវបានគេយកមកកែច្នៃឡើងវិញ ដើម្បីបំប្លែងភាពសុទ្ធរបស់វានិងធ្វើអោយចំនួនគ្រាប់កើនឡើង ។

### ១.២-ប្រេងម្រះព្រៅភ្នំ (Safrole Rich Oils )

ក្នុងឆ្នាំនេះ អាជ្ញាធរមានសមត្ថកិច្ច ខេត្តពោធិសាត់ និង បាត់ដំបង បានបន្តរកឃើញទីតាំងស្តុកប្រេងម្រះព្រៅភ្នំ ដោយបានធ្វើការរឹបអូសផលិតផលក្នុងចំនួនគួរកត់សំគាល់ ។ នេះជាសញ្ញាបញ្ជាក់ថាការផលិតប្រេងម្រះព្រៅភ្នំខុសច្បាប់នៅតែបន្តកើតមាន ។

**២-ការចរាចរណ៍ចែកចាយ**

តំបន់ត្រីកោណមាសនៅតែជាប្រភពដ៏សំខាន់នៃហេរ៉ូអ៊ីននិងគ្រឿងញៀនសំយោគATS សំរាប់ការចរាចរជាលក្ខណៈអន្តរជាតិ ហើយកម្ពុជាបានក្លាយជាប្រទេសរងគ្រោះដោយការចរាចរគ្រឿងញៀនឆ្លងកាត់ ក្នុងនោះព្រលានយន្តហោះអន្តរជាតិភ្នំពេញគឺជាច្រកនាំចេញដ៏សំខាន់ ។ **ទិសខេត្តស្ទឹងត្រែង** ឧក្រិដ្ឋជនបាននាំចូលតាមផ្លូវទឹកនិងផ្លូវគោក ឆ្លងកាត់បណ្តាខេត្តតាមដងទន្លេមេគង្គ ឆ្ពោះមកកាន់ទីក្រុងភ្នំពេញដើម្បីចែកចាយទៅបណ្តាខេត្តផ្សេងៗ ហើយមួយចំនួននាំទៅតំបន់ព្រំដែនភាគពាយ័ព្យនិងមួយចំនួនទៀតនាំទៅតំបន់ព្រំដែនភាគខាងកើត ។ **ទិសខេត្តព្រះវិហារ** ឧក្រិដ្ឋជនបាននាំឆ្លងកាត់ខេត្តឧត្តរមានជ័យឆ្ពោះទៅបណ្តាខេត្តព្រំដែនភាគពាយ័ព្យ (ពិសេសតំបន់ប៉ោយប៉ែត) ។

**៣-ការប្រើបំពានគ្រឿងញៀន**

តាមការកត់សំគាល់អ្នកប្រើប្រាស់គ្រឿងញៀនជាយុវវ័យ មានចំនួនច្រើនជាងគេក្នុងចំណោមអ្នកប្រើបំពានគ្រឿងញៀននៅកម្ពុជា ជាពិសេសចាប់ពីអាយុ១៨ឆ្នាំទៅ២៥ឆ្នាំ មានប្រហែល៥៩,៦% ពី១០ទៅ១៧ឆ្នាំមានប្រហែល១៦,៩% ។ ក្នុងនោះ អ្នកធ្វើការដោយកម្លាំងមានប្រហែល៣៧,៨%, ក្មេងអនាថាប្រហែល១៦,៨%, សិស្សប្រហែល១៥,៤%, អ្នកគ្មានការងារធ្វើប្រហែល១៤% ។ គ្រឿងញៀនសំយោគ**ATS** (មេតំហ្វេតាមីនគ្រាប់និងមេតំហ្វេតាមីនទឹកកក(ICE) គឺជាគ្រឿងញៀនដែលមានការប្រើប្រាស់ច្រើននៅក្នុងប្រទេស បន្ទាប់មកគឺ ហេរ៉ូអ៊ីន, ការហិត, កញ្ឆា, អ៊ិចស្តាស៊ី ។

ការប្រើប្រាស់គ្រឿងញៀនដែលបង្កការបារម្ភខ្លាំងគឺការប្រើប្រាស់ដោយការចាក់ ដោយសារវិធីនេះបានចម្លងមេរោគអេដស៍ និងមេរោគឆ្លងផ្សេងៗជាច្រើន ។ ពីមុនមកការប្រើប្រាស់គ្រឿងញៀនដោយការចាក់ច្រើនកើតមាននៅក្នុងទីក្រុងភ្នំពេញ ប៉ុន្តែបច្ចុប្បន្នវិធីនេះបានរីករាលដាលទៅដល់ខេត្ត-ក្រុងផ្សេងៗ និងទីប្រជុំជនសំខាន់ៗមួយចំនួន ។

## II / **លទ្ធផលនៃកិច្ចប្រតិបត្តិការ :**

**១-ការងារអនុវត្តច្បាប់**

**១.១-ការងារបង្ក្រាបបទល្មើស**

ឆ្នាំនេះ អង្គភាពអនុវត្តន៍ច្បាប់គ្រប់ផ្នែកបានបន្តយកចិត្តទុកដាក់បង្ក្រាបបទល្មើសគ្រឿងញៀនទទួលបានលទ្ធផលដូចខាងក្រោម :

➥**បទល្មើស** បង្ក្រាបបាន **១៩៨** ករណី (ឆ្នាំ២០០៧ មាន **១៥២** ករណី)

➥**ឃាត់ខ្លួនជនល្មើស** **៣៩៤** នាក់(ឆ្នាំ២០០៧ មាន **២៧៩** នាក់)

➥**វត្ថុតាងដកហូត** រួមមាន :

–**មេតំហ្វេតាមីនគ្រាប់ ១១៦.៧៧២** គ្រាប់ (២០០៧ មាន **៣៩០.៩៨៧** គ្រាប់)

–**មេតំហ្វេតាមីនICE ១.៩៣៣,០៥** ក្រាម+**១៥**កូនកញ្ចប់ (ឆ្នាំ២០០៧មាន៦.៧៥០,៥៨ ក្រាម)

–**អ៊ិចស្តាស៊ី ៣៣** គ្រាប់

-**ហេរ៉ូអ៊ីន ៥.២៨៧,៣៩** ក្រាម (ឆ្នាំ២០០៧ មាន **១២.៤៣០,៥០** ក្រាម)

-**កូកាអ៊ីន ១៥០** ក្រាម

-**កញ្ឆាក្រៀម ៤.៩៨៣,៩៨** ក្រាម

-**កូដេអ៊ីន** (ឱសថប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ) ចំនួន **១០.១៦១** គ្រាប់និងវត្ថុតាងពាក់ព័ន្ធជាច្រើនទៀត

-**កេតាមីន** ចំនួន **២០** ប្រអប់ ស្មើនឹង **៤៩៥** ដប

**១.២-លទ្ធផលវិភាគសំណាកវត្ថុតាង**

មន្ទីរពិសោធន៍គ្រឿងញៀននៃអគ្គលេខាធិការដ្ឋាន អជបគញ បានទទួលធ្វើកោសល្យវិច័យលើសំណាកវត្ថុតាងដែលតុលាការ និងអង្គភាពអនុវត្តន៍ច្បាប់គ្រប់ផ្នែកបញ្ជូនមកបានចំនួន**១៥២**សំណាក ។ ក្នុងនោះ សំណាក **អវត្តមាន** ចំនួន **៦៥** សំណាក, សំណាក **វត្តមាន** ចំនួន**២១០** សំណាកគឺ កញ្ឆា៤សំ-ណាក, អ៊ិចស្តាស៊ី**៧**សំណាក, មេតំហ្វេតាមីនទឹកកក (**ICE**) **២** សំណាក, មេតំហ្វេតាមីនគ្រាប់ **១៨១** សំណាក, ហេរ៉ូអ៊ីន **៧** សំណាក, (ឱសថប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ : **Ketamine** **៤** សំណាក), **Ephedrine** (សារធាតុគីមីផ្សំគ្រឿងញៀនសំយោគ**ATS**) **១** សំណាក, នីមេតាហ្សីបាម ១ សំណាក, កូកាអ៊ីន ៣ សំណាក ។

**១.៣-លទ្ធផលបំផ្លាញវត្ថុតាងគ្រឿងញៀន**

-ស្នងការដ្ឋាននគរបាលខេត្តក្រចេះ បានធ្វើការកាប់បំផ្លាញដំណាំកញ្ឆាលើផ្ទៃដី ១០១,៦ ម$^{២}$ ។

-ខេត្តពោធិសាត់ បង្ក្រាបកន្លែងលួចលាក់ស្តុកប្រេងម្រះព្រៅនៅក្នុងភូមិពីរស្ថិតក្នុងឃុំវាលរាម ស្រុកវាលវែង និងដកហូតបានប្រេងម្រះព្រៅចំនួន ២៥ តោន ។

-ខេត្តកំពង់ចាម បានបំផ្លាញសារធាតុគីមីផ្សំ (**Methylene Chloride.MC**) ចំនួន ៣.១១០$^{គ.ក្រ}$ ។

-សាលាក្រុងភ្នំពេញ បានធ្វើការដុតបំផ្លាញវត្ថុតាងគ្រឿងញៀនរួមមាន មេតំហ្វេតាមីនចំនួន **២៤៩.១២៤**គ្រាប់, មេតំហ្វេតាមីនទឹកកក **១៧.៥៨២,១៧**ក្រាម, អ៊ិចស្តាស៊ី **៣៣២**គ្រាប់, អូផ្យូមអាល់កាឡូអ៊ីដ **១៦**គ្រាប់, ថ្នាំញៀនបន្ទុះ **២៨០**គ្រាប់, ថ្នាំបន្សាប **៣**គ្រាប់, ហេរ៉ូអ៊ីន **១៣.៧៣៧,៦៨**ក្រាម, សារធាតុផ្សំ **២៤៥.២០០**ក្រាម, កញ្ឆាគ្រីប **៣៥០០**ក្រាម, កញ្ឆាក្រៀម **១.៤០០**ក្រាម, បារីកញ្ឆា **៤៥**ដើម (ក្នុងឱកាសអបអរសាទរទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ២៦មិថុនា២០០៨) ។

**១.៤-ការពង្រឹងរចនាសម្ព័ន្ធរដ្ឋបាលត្រួតពិនិត្យគ្រឿងញៀន និង សមត្ថភាពអនុវត្តច្បាប់**

អគ្គលេខាធិការដ្ឋាន អជបគញ បានបន្តយកចិត្តទុកដាក់លើការពង្រឹងសមត្ថភាពអនុវត្តច្បាប់ មានដូចតទៅ :

**ក/ ការពង្រឹងរចនាសម្ព័ន្ធរដ្ឋបាលត្រួតពិនិត្យគ្រឿងញៀនខេត្ត-ក្រុង :**

ដោយបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពីឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រធាន អជបគញ នៅថ្ងៃទី២១ ខែឧសភាឆ្នាំ២០០៨ អគ្គលេខាធិការដ្ឋាន អជបគញ បានរៀបចំកិច្ចប្រជុំគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្ត-ក្រុង ដើម្បីត្រួតពិនិត្យលទ្ធផលការងារឆ្នាំ២០០៧ ។ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី

បានណែនាំដល់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្ត-ក្រុង ដូចតទៅ ៖

១-ត្រូវបន្តមានវិធានការជាបន្ទាន់ចំពោះតំបន់ទាំងឡាយ ដែលមានសកម្មភាពលក់ចែកចាយ និងប្រើប្រាស់ដើម្បីកាត់បន្ថយភាពអនាធិបតេយ្យ, អសន្តិសុខក្នុងមូលដ្ឋាននិងសណ្តាប់ធ្នាប់សាធារណៈ។

២-ត្រូវបន្តក្តាប់មុខសញ្ញាប្រព្រឹត្តបទល្មើស និងធ្វើការប្រមូលទិន្នន័យអ្នកញៀនគ្រឿងញៀនឱ្យបានច្បាស់លាស់ ដើម្បីឈានទៅអនុវត្តឱ្យបានជោគជ័យនូវគោលការណ៍ប្រៀបសមរភូមិប្រឆាំងបទល្មើសគ្រឿងញៀនរបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

៣-ត្រូវបន្តជំរុញលើកទឹកចិត្តឱ្យមានការចូលរួមពីផ្នែកឯកជន ពីប្រព័ន្ធផ្សព្វផ្សាយ និងអង្គការមិនមែនរដ្ឋាភិបាលនានា ដើម្បីពង្រឹងនិងពង្រីកយន្តការផ្សព្វផ្សាយអប់រំ ឱ្យកាន់តែមាននិរន្តរភាព និងវិសាលភាពទូលំទូលាយជ្រួតជ្រាបដល់គ្រប់មជ្ឈដ្ឋានប្រជាពលរដ្ឋ ។ ចំពោះក្រុមការងារបង្ការទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀននៅក្នុងសាលារៀនដែលអាជ្ញាធរជាតិបានណែនាំឱ្យបង្កើត ខេត្ត-ក្រុងទាំងឡាយណាដែលមិនទាន់បានបង្កើតត្រូវរូតរះបង្កើតឡើង និងចាប់ផ្តើមអនុវត្តឱ្យបានឆាប់រហ័ស ។

៤-ចំពោះខេត្តក្រុង ដែលមិនទាន់បានបង្កើតមជ្ឈមណ្ឌលសំរាប់ព្យាបាលអ្នកញៀនគ្រឿងញៀន ត្រូវពិចារណារកកន្លែងទុកដាក់អ្នកទាំងនោះ ក្នុងគោលបំណងលើកកំពស់សុខុមាលភាពជនរងគ្រោះ និងរួមចំណែកក្នុងការរក្សានូវសន្តិសុខសណ្តាប់ធ្នាប់សុវត្ថិភាពសង្គមក្នុងខេត្ត-ក្រុងរបស់ខ្លួន ។

៥-ចំពោះខេត្ត-ក្រុង ដែលមិនទាន់មានលេខាធិការដ្ឋាន ឬមិនទាន់បានជ្រើសរើសមន្ត្រីឱ្យមកបំរើការងារជាប្រចាំនៅក្នុងលេខាធិការដ្ឋាននៃគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន ត្រូវរៀបចំបង្កើត និងរៀបចំរចនាសម្ព័ន្ធ របៀបរបបការងារ ក្នុងលេខាធិការដ្ឋានឱ្យបានល្អប្រសើរ ។

ចំពោះបញ្ហាថវិកាសំរាប់ការងារប្រយុទ្ធប្រឆាំងគ្រឿងញៀនរបស់ខេត្ត-ក្រុង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានសំរេចផ្តល់ជូនខេត្ត-ក្រុង នូវថវិកាក្នុងចំនួនសមស្របដែលអាចអនុវត្តការងារប្រយុទ្ធប្រឆាំងគ្រឿងញៀនក្នុងឆ្នាំ២០០៨ ។ នៅក្នុងឱកាសនៃកិច្ចប្រជុំ ឯកឧត្តមឧបនាយករដ្ឋមន្ត្រីបានផ្តល់ប័ណ្ណសរសើរជូនដល់ប្រធានគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនគ្រប់ខេត្ត-ក្រុង និងអង្គភាពជំនាញរួមមាន មន្ទីរប្រឆាំងគ្រឿងញៀន, កងរាជអាវុធហត្ថលើផ្ទៃប្រទេស និង អង្គភាពគយ-រដ្ឋាករ ។

## ខ/ ការពង្រឹងសមត្ថភាពអនុវត្តច្បាប់ ៖

### ខ.១/ ការពង្រឹងសមត្ថភាពមន្ទីរពិសោធន៍គ្រឿងញៀន អជបគញ ៖

បច្ចុប្បន្ននេះ មន្ទីរពិសោធន៍របស់អគ្គលេខាធិការដ្ឋានមានម៉ាស៊ីនវិភាគគ្រឿងញៀនប្រភេទ GC(Gas Chromatography) មួយគ្រឿង ជាជំនួយរបស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន និងម៉ាស៊ីនវិភាគមួយគ្រឿងទៀតប្រភេទGC-MS ជាជំនួយរបស់សាធារណរដ្ឋបារាំង ។

មន្ទីរពិសោធន៍ មានលទ្ធភាពគ្រប់គ្រាន់ក្នុងការធ្វើកោសល្យវិច័យរកសារធាតុញៀន ដែលមាននៅក្នុងសំណាក ដើម្បីប្រើប្រាស់ជាមូលដ្ឋានក្នុងការចោទប្រកាន់ ។ បុគ្គលិកមន្ទីរពិសោធន៍ បានទទួលនូវការបណ្តុះបណ្តាលពីបច្ចេកទេសវិភាគបរិមាណនិងគុណភាព, ការប្រមូលទិន្នន័យ និងបច្ចេកទេស

ក្នុងការចងក្រងភាពមិនសុទ្ធនៃសំណាក ។ ប៉ុន្តែដោយសារសម្ភារៈបរិក្ខាររបស់មន្ទីរពិសោធន៍នៅមានកំរិត ទើបមន្ទីរពិសោធន៍ពុំទាន់មានលទ្ធភាពគ្រប់គ្រាន់ក្នុងការចងក្រងភាពមិនសុទ្ធនៃសំណាក ។

ចំពោះខេត្ត-ក្រុង អគ្គលេខាធិការដ្ឋានបានផ្តល់ជូននូវតេស្តឃីត (Test Kit) សំរាប់ធ្វើការវិភាគបឋមទៅលើសំណាកសង្ស័យដែលដកហូតបានភ្លាមៗ ។ **ថ្មីៗនេះ** អគ្គលេខាធិការដ្ឋានទទួលបានការគាំទ្រពីអង្គការ JICA និងក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនថៃ (ONCB) ក្នុងការជួយបង្កើតមន្ទីរពិសោធន៍ខ្នាតតូចសំរាប់ថ្នាក់តំបន់ ។

**ខ.២/ ការពង្រឹងសមត្ថភាពមន្ត្រីអនុវត្តន៍ច្បាប់ :**

ការងារនេះ អគ្គលេខាធិការដ្ឋាន អជបគញ បាន :

☛ **សហការជាមួយការិយាល័យគ្រឿងញៀននិងឧក្រិដ្ឋកម្ម អ.ស.ប( UNODC)** រៀបចំសិក្ខាសាលា ដែលក្នុងនោះរួមមាន :

-សិក្ខាសាលាផ្សព្វផ្សាយការអនុវត្តន៍ប្រកាសរបស់ក្រសួងសុខាភិបាល ស្តីពីការដាក់បញ្ចូលប្រេងម្រះព្រៅភ្នំទៅក្នុងតារាងឧបសម្ព័ន្ធនៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន (២៧/១២/២០០៧) ។

-សិក្ខាសាលា ដើម្បីពិនិត្យកែសំរួលលើសេចក្តីព្រាងគោលការណ៍ណែនាំសំរាប់ការត្រួតពិនិត្យប្រេងម្រះព្រៅភ្នំ និងការដាក់ចេញនូវវិធានការដាក់ស្តែងសំរាប់ទប់ស្កាត់ ការផលិត ការចរាចរ ការជួញដូរ ការចែកចាយ ការរក្សាទុក និង ការធ្វើពាណិជ្ជកម្មក្នុងប្រទេសនិងអន្តរជាតិនូវប្រេងម្រះព្រៅភ្នំ (០៥-០៦/៣/២០០៨) ។

-សិក្ខាសាលាអនុតំបន់ សំរាប់មន្ត្រីទំនាក់ទំនងព្រំដែន (**BLO**) ចំនួន៦ប្រទេសគឺ កម្ពុជា ឡាវ ថៃ វៀតណាម មីយ៉ាន់ម៉ា ចិន (សៀមរាប ២៨-៣០/៤/២០០៨) ដើម្បីរៀបចំយុទ្ធសាស្ត្រត្រួតពិនិត្យគ្រឿងញៀនសំរាប់ឆ្នាំ២០០៨-២០១១ និងពិភាក្សាពីលទ្ធភាពទប់ស្កាត់ឧក្រិដ្ឋកម្មឆ្លងប្រទេសដូចជាការជួញដូរគ្រឿងញៀន ការជួញដូរមនុស្ស និងការការពារបរិស្ថាន ដោយប្រើប្រាស់យន្តការនៃការិយាល័យ **BLO** ដែលមានស្រាប់ ក្រោមគំរោង I61 របស់ UNODC ។

**ក្រោយពីនោះ UNODC** តំបន់ បានបន្តកិច្ចសហការជាមួយអគ្គលេខាធិការដ្ឋានក្នុងការ :

-ចងក្រងទម្រង់នីតិវិធីតាមបទដ្ឋានបច្ចេកទេស ដែលមានសុវត្ថិភាពសំរាប់ប្រតិបត្តិការបង្ក្រាបមន្ទីរពិសោធន៍គ្រឿងញៀនលួចលាក់ ។

-សិក្សាពីច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ចំពោះមាត្រាពាក់ព័ន្ធនឹងស្ថានទម្ងន់ទោស និងបទដ្ឋានគតិយុត្តិដែលពាក់ព័ន្ធនឹងការគ្រប់គ្រងនិងត្រួតពិនិត្យសារធាតុគីមីផ្សំ, សារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ និង សារធាតុញៀនស្របច្បាប់ និងស្វែងយល់ពីការអនុវត្តន៍ច្បាប់ ដើម្បីឈានទៅធ្វើការវាយតម្លៃ និងបង្កើតបានជាអនុសាសន៍ក្នុងការគ្រប់គ្រងនិងត្រួតពិនិត្យលើសារធាតុគីមីផ្សំ សារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ និង សារធាតុញៀនស្របច្បាប់ ។

តាមរយៈ គំរោងស្តីពីការកែទម្រង់ស្ថាប័ននិងពង្រឹងសមត្ថភាពដើម្បីត្រួតពិនិត្យនិងបញ្ចូលការ

បង្ការការប្រើបំពានគ្រឿងញៀននៅកម្ពុជា (គំរោងAD11) អគ្គលេខាធិការដ្ឋាន បានទទួលម៉ាស៊ីនថតចម្លង១គ្រឿង (១៦/៧/២០០៨) ពីការិយាល័យតំណាងការិយាល័យUNODC ប្រចាំទីក្រុងភ្នំពេញ ។

☛ **សហការជាមួយទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន(JICA)** រៀបចំសិក្ខាសាលានិងវគ្គបណ្តុះបណ្តាល ដែលក្នុងនោះរួមមាន :

- សិក្ខាសាលាយល់ដឹងពីសភាពការណ៍គ្រឿងញៀននៅកម្ពុជា, យល់ដឹងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និង ចំណេះដឹងជាមូលដ្ឋានអំពីគ្រឿងញៀន ។
- សិក្ខាសាលា និង វគ្គបណ្តុះបណ្តាល មន្ត្រីអនុវត្តច្បាប់លើការងារត្រួតពិនិត្យគ្រឿងញៀន, របៀបធ្វើតេស្តគ្រឿងញៀនជំហានដំបូង, ការផ្លាស់ប្តូរបទពិសោធន៍លើការអនុវត្តន៍ច្បាប់ត្រួតពិនិត្យគ្រឿងញៀន, ការប្រើប្រាស់ព័ត៌មានវិភាគគ្រឿងញៀន, ការវិភាគនិងការប្រមូលព័ត៌មានគ្រឿងញៀន, ការប្រគល់ដោយមានការឃ្លាំមើល, វិធីសាស្ត្រក្នុងការត្រួតពិនិត្យផែកឆេះរថយន្ត, ការត្រួតពិនិត្យសារធាតុគីមីផ្សំ, ការគ្រប់គ្រងភ្នាក់ងារសម្ងាត់ផ្តល់ព័ត៌មាន ។

ជាមួយនោះ អគ្គលេខាធិការដ្ឋាន អជបគញ បានទទួលនូវសម្ភារៈរួមមាន :

–សម្ភារៈសំរាប់ការពង្រឹងសមត្ថភាពមន្ទីរពិសោធន៍គ្រឿងញៀន និង ពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់ តាមរយៈការប្រើប្រាស់លទ្ធផលនៃការវិភាគលើលក្ខណៈរូបនិងភាពសុទ្ធនៃគ្រឿងញៀន (ថ្ងៃទី២៥/០១/២០០៨) ។

–ជញ្ជីងអេឡិចត្រូនិចសំរាប់ថ្លឹងគ្រឿងញៀន ដែលបានផ្តល់ជូនខេត្ត–ក្រុងចំនួន១៨ និង មន្ទីរប្រឆាំងគ្រឿងញៀន, កងរាជអាវុធហត្ថលើផ្ទៃប្រទេស, អង្គភាពគយ–រដ្ឋាករព្រលានយន្តហោះអន្តរជាតិក្រុងភ្នំពេញ ខេត្តសៀមរាប ក្រុងព្រះសីហនុ (នៅថ្ងៃទី២១/៥/២០០៨) ។

–វិទ្យុទាក់ទង ចំនួន១០គ្រឿង និង ម៉ាស៊ីនថត ចំនួន២គ្រឿង សំរាប់ចែកជូនខេត្តកោះកុង និង ក្រុងព្រះសីហនុ ដោយក្នុងមួយខេត្ត–ក្រុងទទួលបាននូវ វិទ្យុទាក់ទងចំនួន៥គ្រឿង និង ម៉ាស៊ីនថតចំនួន១គ្រឿង និងឧបករណ៍វិភាគគ្រឿងញៀន, សៀវភៅគ្រឿងញៀនមួយចំនួនទៀត ។

គំរោងទ្វេភាគីកម្ពុជា–ជប៉ុនតាមរយៈអង្គការJICA ស្តីពីការត្រួតពិនិត្យគ្រឿងញៀននៅកម្ពុជានឹងត្រូវបន្តអាណត្តិរបស់ខ្លួនចាប់ ពីខែមេសាឆ្នាំ២០០៨ ដល់ ខែមីនា ឆ្នាំ២០០៩ ។ ហើយតាមរយៈ កិច្ចពិភាក្សាការងារជាមួយមន្ត្រីជាន់ខ្ពស់ផ្នែកគោលនយោបាយសាធារណៈ និងកម្មវិធីរបស់អង្គការ**JICA** នៅទីក្រុងតូក្យូ (ថ្ងៃទី០៥/៥/២០០៨) បានពិនិត្យលទ្ធភាពជួយដល់អគ្គលេខាធិការដ្ឋាន អជបគញ លើការបណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់កម្ពុជា នៅឯប្រទេសជប៉ុន និង បញ្ជូនអ្នកឯកទេស ពីប្រទេសជប៉ុនមកធ្វើការហ្វឹកហ្វឺនមន្ត្រីអនុវត្តច្បាប់នៅកម្ពុជាលើមុខជំនាញវិភាគគ្រឿងញៀន,ជំនាញត្រួតពិនិត្យគ្រឿងញៀនតាមច្រកទ្វារអន្តរជាតិ ។

☛ **កិច្ចសហប្រតិបត្តិការទ្វេភាគី ក្នុងក្របខ័ណ្ឌ អាស៊ាន–កូរ៉េ** អគ្គលេខាធិការដ្ឋាន អជបគញ បានផ្តល់លទ្ធភាពជូនអគ្គរដ្ឋអាជ្ញានៃសាធារណរដ្ឋកូរ៉េក្នុងការបើកការិយាល័យទំនាក់ទំនង (ហៅកាត់

ថា **LOICOG** ) ។ ដើម្បីចាប់ផ្តើមដំណើរការអនុវត្តន៍គំរោង " ស្តីពីការផ្តល់សមត្ថភាពជំនាញត្រួតពិនិត្យគ្រឿងញៀនដល់មន្ត្រីអនុវត្តច្បាប់នៅបណ្តាប្រទេសក្នុងសមាគមអាស៊ាន " សំរាប់ប្រទេសកម្ពុជា ដែលមានរយៈពេល៩ខែ ភាគីកូរ៉េបានផ្តល់សម្ភារៈមួយចំនួននៅថ្ងៃទី២៥ខែមីនាឆ្នាំ២០០៨ ។

ដើម្បីបន្តគំរោងខាងលើ អគ្គលេខាធិការ អជបគញ បានពិភាក្សាជាមួយអ្នកសម្របសម្រួលគំរោងនៅថ្ងៃទី១២/៩/២០០៨ ដើម្បីប្តូរគំរោងខាងលើពីក្នុងក្របខណ្ឌអាស៊ាន-កូរ៉េ មកជាគំរោងទ្វេភាគី កម្ពុជា-កូរ៉េ ដែលមានរយៈពេលយូរជាង ។

☛ **តាមរយៈកិច្ចសហប្រតិបត្តិការទ្វេភាគី កម្ពុជា-បារាំង** អគ្គលេខាធិការដ្ឋាន អជបគញ បានទទួលការគាំទ្រលើការពង្រឹងសមត្ថភាពមន្ទីរពិសោធន៍គ្រឿងញៀន, ការបណ្តុះបណ្តាលសមត្ថភាពមន្ត្រីអនុវត្តន៍ច្បាប់ និងការងារលើកកំពស់ការយល់ដឹងពីគ្រឿងញៀន ។

**ទន្ទឹមនោះ** ដោយបានការអនុញ្ញាតពីឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ស ខេង** ប្រធាន អជបគញ និងបានការអញ្ជើញពីភាគីបារាំង ឯកឧត្តម **គេង សាវឌ្ឍ** អនុប្រធានអចិន្ត្រៃយ៍ អជបគញ បានដឹកនាំប្រតិភូទៅទស្សនកិច្ចសិក្សាស្វែងយល់និងដកបទពិសោធន៍អំពីរចនាសម្ព័ន្ធ តួនាទី ភារកិច្ច របស់អង្គភាពបេសកកម្មជាតិត្រួតពិនិត្យសារធាតុគីមីផ្សំ នៃសាធារណរដ្ឋបារាំង ។

☛ **តាមរយៈកិច្ចសហប្រតិបត្តិការទ្វេភាគីជាមួយក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនថៃ (ONCB )**

អគ្គលេខាធិការដ្ឋាន អជបគញ បានទទួលការគាំទ្រពីភាគីថៃដូចតទៅ :

**១)** ភាគីថៃ ជួយបង្កើតការិយាល័យទំនាក់ទំនងព្រំដែន (**BLO** ) រវាងខេត្តព្រះវិហារជាមួយខេត្តអ៊ូប៊ុន (ប្រទេសថៃ) ។

**២)** ភាគីថៃ បានបណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់ និងមន្ត្រីទំនាក់ទំនងព្រំដែន (**BLO** ) របស់ខេត្តឧត្តរមានជ័យបានចំនួន២០នាក់, ខេត្តព្រះវិហារបានចំនួន១០នាក់ នៅខេត្តនគររាជសីមា (ប្រទេសថៃ) កាលពីថ្ងៃទី ២៦ ដល់ ថ្ងៃទី៣០/៥/២០០៨ ។

**៣)** ភាគីថៃ បានផ្តល់កាណូតល្បាតចំនួន២គ្រឿង ដល់ខេត្តស្ទឹងត្រែងសំរាប់កិច្ចប្រតិបត្តិការតាមដងទន្លេមេគង្គ និងត្រៀមផ្តល់កាណូតល្បាតចំនួន២គ្រឿងបន្ថែមទៀតសំរាប់ការិយាល័យBLOកម្ពុជា ។

**៤)** ភាគីថៃ នឹងជួយសម្ភារៈបន្ថែមសំរាប់ការិយាល័យBLO ខេត្តស្ទឹងត្រែង ខេត្តឧត្តរមានជ័យ និងខេត្តព្រះវិហារ ។

**៥)** ភាគីថៃ នឹងពង្រឹងសមត្ថភាពជំនាញដល់មន្ត្រីការិយាល័យទំនាក់ទំនងព្រំដែន (BLO ) ដែលទើបបង្កើតថ្មីនៅខេត្តឧត្តរមានជ័យ ព្រះវិហារ (កម្ពុជា) និងខេត្តចំប៉ាសាក់ (ឡាវ) ។

**៦)** ភាគីថៃនឹងផ្តល់តេស្តគ្រឿងញៀនដល់មន្ត្រីអនុវត្តន៍ច្បាប់ខេត្តឧត្តរមានជ័យ ខេត្តព្រះវិហារ និងស្ទឹងត្រែង ។

**៧)** ភាគីថៃ បានផ្តល់ប៉ាណូចំនួន៤ផ្ទាំង ដែលមានខ្លឹមសារផ្សព្វផ្សាយពីច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀននៅព្រះរាជាណាចក្រកម្ពុជា និងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀននៅព្រះរាជាណា-

ចក្រថៃ សំរាប់ដាក់នៅច្រក**ចាំយាម** (កោះកុង) ច្រក**ព្រំ** (ប៉ៃលិន) ច្រក**ដូង** (បាត់ដំបង) ច្រក**ប៉ោយប៉ែត** (បន្ទាយមានជ័យ) ។

**៨)** ភាគីថៃ បានហ្វឹកហ្វឺនដល់មន្ត្រីអគ្គលេខាធិការដ្ឋាន អជបគញ ចំនួន២រូប និងមន្ត្រីអនុវត្តន៍ច្បាប់ខេត្តសៀមរាប បាត់ដំបង បន្ទាយមានជ័យ សរុបចំនួន៤០រូប ដែលបំរើការ នៅតាមមជ្ឈមណ្ឌលព្យាបាលស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ពីការងារព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀននៅទីក្រុងប៉ាតាយ៉ាប្រទេសថៃ (១៩-២២/៨/២០០៨) ។

**ដោយឡែក** ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ស ខេង** ប្រធាន អជបគញ បានជួបជាមួយឯកឧត្តម **Sampong Amornvivat** រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងជាប្រធានក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនថៃ ដែលអញ្ជើញមកធ្វើទស្សនកិច្ចនៅកម្ពុជា (១៨/៦/២០០៨) ។ ឯកឧត្តម **Sampong Amornvivat** បានជំរាបពីជំហររបស់រដ្ឋាភិបាលថៃក្នុងការរឹតចំណងសាមគ្គីភាព កិច្ចសហប្រតិបត្តិការល្អប្រសើរ និងការត្រៀមលក្ខណៈជាស្រេចដើម្បីបណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់កម្ពុជា, ការផ្តល់នូវសម្ភារៈសំរាប់កិច្ចប្រតិបត្តិការបង្ក្រាបបទល្មើសរួមទាំងជំនួយផ្នែកកិច្ចការច្បាប់ផង ។

**☛ តាមរយៈសហប្រតិបត្តិការទ្វេភាគី ជាមួយស្ថាប័នប៉ូលីសសហព័ន្ធអូស្ត្រាលី** (**AFP**) អគ្គលេខាធិការដ្ឋាន អជបគញ ទទួលបានការគាំទ្រទាំងថវិកានិងបច្ចេកទេស ក្នុងការដុតបំផ្លាញប្រេងម្រះព្រៅភ្នំចំនួន៣៥តោន ។ ពិធីនេះធ្វើនៅ ភូមិទួលគ្រួស ឃុំចំរើនផល ស្រុកសំពៅមាស ខេត្តពោធិសាត់ ចាប់ពីថ្ងៃទី១៦រហូតដល់ថ្ងៃទី២០ខែមិថុនាឆ្នាំ២០០៨ ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិត**ចាន់ សារុន**រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ, ឯកឧត្តម **តេខ សាវឌ្ឍ** អនុប្រធានអចិន្ត្រៃយ៍ អជបគញ, ឯកឧត្តម **លួ រ៉ាមីន** អគ្គលេខាធិការ អជបគញ និងមានការអញ្ជើញចូលរួមជាកិត្តិយសពីឯកឧត្តម **ឌី សុគន្ធ** ប្រធានរដ្ឋបាលព្រៃឈើ, លោកស្រី **FIONA COCHAUD** តំណាងស្ថានទូតសហព័ន្ធអូស្ត្រាលីប្រចាំនៅកម្ពុជា, ឯកឧត្តម **ឆាយ សាវ៉េត** អភិបាលខេត្តពោធិសាត់ ព្រមទាំងនាយខណ្ឌរដ្ឋបាលព្រៃឈើទាំង៣ខេត្ត និងអ្នកកាសែតជាតិ អន្តរជាតិ ជាច្រើនរូប ។

ជាមួយនេះ ស្ថាប័នប៉ូលីសសហព័ន្ធអូស្ត្រាលីបានសហការជាមួយអគ្គលេខាធិការដ្ឋាន បើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីអនុវត្តច្បាប់ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ពីថ្ងៃទី២០ ដល់ ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៨ ហើយ **AFP** និង **UNODC** បានជួយអគ្គលេខាធិការដ្ឋាន ដើម្បីបញ្ចប់អោយបានឆាប់រហ័សនូវសេចក្តីព្រាងស្តីពី ទម្រង់បទដ្ឋានបច្ចេកទេសដែលមានសុវត្ថិភាពសំរាប់ប្រើប្រាស់ក្នុងកិច្ចប្រតិបត្តិការបង្ក្រាបមន្ទីរពិសោធន៍គ្រឿងញៀនលួចលាក់ ។

ដើម្បីជំរុញកិច្ចសហប្រតិបត្តិការជាមួយកម្ពុជាកាន់តែមានប្រសិទ្ធិភាពAFP កំពុងរៀបចំអនុស្សារណៈនៃការយោគយល់គ្នា (**MOU**) ទ្វេភាគី អជបគញ-**AFP** ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

**☛ តាមរយៈសហប្រតិបត្តិការទ្វេភាគី ជាមួយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនចិន**

អគ្គលេខាធិការដ្ឋាន អជបគញ បានរៀបចំដំណើរទស្សនកិច្ចជូនគណៈប្រតិភូ អជបគញ ដែល

ដឹកនាំដោយឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ស ខេង** ប្រធាន អជបគញ ទៅធ្វើទស្សនកិច្ចផ្លូវការ នៅសាធារណរដ្ឋប្រជាមានិតចិន (នៅថ្ងៃទី០៣-០៨/១១/២០០៨) ដើម្បីចុះហត្ថលេខាលើអនុស្សារណៈនៃការយោគយល់គ្នាទ្វេភាគី ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន ។ នៅក្នុងកម្មវិធីទស្សនកិច្ចនេះ ភាគីកម្ពុជា-ចិន នឹងលើកមកពិភាក្សាផងដែរលើការងារសន្តិសុខ ដែលក្នុងនោះរួមមាន ការប្រឆាំងភេរវកម្ម, ឧក្រិដ្ឋកម្មឆ្លងដែន, ការជួញដូរមនុស្ស និង ការលាងលុយកខ្វក់ ។

គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនចិន បានផ្តល់លទ្ធភាពអោយមន្ត្រីអនុវត្តច្បាប់កម្ពុជាទៅសិក្សានៅសាលានគរបាលខេត្តយូណាន់ ស្តីពីការងារត្រួតពិនិត្យគ្រឿងញៀន ។

**២-ការងារកាត់បន្ថយតម្រូវការគ្រឿងញៀន**

**២.១-សកម្មភាព ផ្សព្វផ្សាយ អប់រំ**

កិច្ចការនេះ អគ្គលេខាធិការដ្ឋាន អជបគញ បានបន្តកិច្ចសហការជាមួយក្រសួងស្ថាប័ន, គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនគ្រប់ខេត្ត-ក្រុង, អង្គការជាតិ/អន្តរជាតិ, អង្គការមិនមែនរដ្ឋាភិបាល ជាដៃគូក្នុងការអនុវត្តកម្មវិធីអប់រំផ្សព្វផ្សាយតាមរយៈសកម្មភាពដូចខាងក្រោម :

-សំរាប់ការអប់រំផ្សព្វផ្សាយតាមគោលដៅ អគ្គលេខាធិការដ្ឋាន បានផ្តល់នូវឯកសារផ្សព្វផ្សាយដូចជា ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងឯកសារផ្សព្វផ្សាយអប់រំផ្សេងៗទៀត ដើម្បីលើកកំពស់ការយល់ដឹងពីគ្រោះថ្នាក់ដែលបណ្តាលមកពីការប្រើបំពានគ្រឿងញៀន នៅតាមវិទ្យាល័យ អនុ-វិទ្យាល័យ ក្នុងក្រុងភ្នំពេញ ក្រុងព្រះសីហនុ ខេត្តសៀមរាប ខេត្តស្ទឹងត្រែង ខេត្តបាត់ដំបង (រួមមាន ស្រុកបាត់ដំបង ស្រុកបាណន់ ស្រុកថ្មគោល ស្រុកកំរៀង ស្រុកសំឡូត ស្រុកភ្នំព្រឹក) ខេត្តក្រចេះ ខេត្តកំពង់ចាម ខេត្តរតនគីរី ខេត្តមណ្ឌលគីរី ខេត្តព្រៃវែង ខេត្តស្វាយរៀង... ដល់លោកគ្រូ-អ្នកគ្រូ និស្សិត សិស្សានុសិស្ស កងទ័ព កងនគរបាល (ស្រុក/ខណ្ឌ-ខេត្ត-ក្រុង), មន្ត្រីរាជការ នៅតាមមន្ទីរនានាចំណុះខេត្ត-ក្រុង, កម្មកររោងចក្រ/សហគ្រាស សរុបបានចំនួន **៦.២៥០** នាក់ ។

**ដោយឡែក** តាមរយៈគំរោងកិច្ចសហប្រតិបត្តិការទ្វេភាគីក្នុងក្របខណ្ឌអាស៊ាន-កូរ៉េស្តីពីការផ្តល់សមត្ថភាពជំនាញត្រួតពិនិត្យគ្រឿងញៀន ដល់មន្ត្រីអនុវត្តន៍ច្បាប់នៅក្នុងសមាគមអាស៊ាន (សំរាប់ប្រទេសកម្ពុជា) ភាគីកូរ៉េបានផ្តល់នូវ ទូរទស្សន៍ ម៉ាស៊ីនចាក់ VCD-DVD ដល់មន្ទីរអប់រំយុវជន និងកីឡារបស់ខេត្តចំនួន៧គឺ ខេត្តស្ទឹងត្រែង ក្រចេះ កំពង់ចាម រតនគីរី មណ្ឌលគីរី ស្វាយរៀង ព្រៃវែង ដោយខេត្តនីមួយៗទទួលបាន ទូរទស្សន៍ចំនួន៣គ្រឿង ម៉ាស៊ីនចាក់ VCD-DVD ចំនួន៣គ្រឿង និងឯក-សារផ្សព្វផ្សាយមួយចំនួន ។

-អគ្គលេខា ធិការដ្ឋាន អជបគញ បានចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់ជាមួយស្ថាប័នរដ្ឋាភិបាល អង្គការអន្តរជាតិ បណ្តាក្រុមហ៊ុនវិនិយោគ... អំពីកម្មវិធីបង្ការទប់ស្កាត់ការឆ្លងមេរោគអេដស៍/ជម្ងឺអេដស៍ ។

-ដោយបានការឧបត្ថម្ភគាំទ្រពីអង្គការ (UNODC) អង្គការសុខភាពពិភពលោក (WHO) អង្គការសុខភាពគ្រួសារអន្តរជាតិ (FHI) ការិយាល័យតំណាងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (**JICA**) អមអគ្គលេខាធិការដ្ឋាន ការិយាល័យទំនាក់ទំនងរបស់អគ្គរដ្ឋអាជ្ញានៃសាធារណរដ្ឋកូរ៉េ (**LOICOG**) អមអគ្គលេខាធិការដ្ឋាន អង្គការសម្ព័ន្ធភាពខ្មែរប្រយុទ្ធនឹងជម្ងឺអេដស៍ (**KHANA**) អគ្គលេខាធិការដ្ឋាន អជបគញ បានសហការផលិតនូវឯកសារផ្សព្វផ្សាយបន្ថែមដូចជា ខិត្តប័ណ្ណ កូនសៀវភៅផ្ទត់ **Poster** បដាកាន់ដៃ បដាចងតាមដងផ្លូវ មួក អាវយឺត សំរាប់ទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ថ្ងៃទី២៦ខែមិថុនា ឆ្នាំ២០០៨ និង ពិធីបុណ្យអុំទូក បណ្តែតប្រទីប អកអំបុក សំពះព្រះខែ ថ្ងៃទី១១ដល់១៣ ខែវិច្ឆិកា ឆ្នាំ២០០៨ ។

-សហការនិងបំផុសគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនគ្រប់ខេត្ត-ក្រុង ឱ្យចូលរួមប្រារព្ធទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ២៦មិថុនា២០០៨ ដែលមានប្រជាជនចូលរួមសរុបប្រមាណជាង **៣០.០០០** នាក់ ។

-សហការជាមួយគំរោងទ្វេភាគី អជបគញ-**JICA** បើកវគ្គបណ្តុះបណ្តាលស្តីពីការលើកកំពស់ការយល់ដឹងជាសាធារណៈអំពីគ្រោះថ្នាក់នៃគ្រឿងញៀន (២៥-២៨/១២/២០០៧) ដល់មន្ត្រីនៃក្រសួងស្ថាប័នរដ្ឋាភិបាល មន្ត្រីតាមមន្ទីរនានាចំណុះខេត្ត-ក្រុង ។

-ចូលរួមក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងាររបស់អង្គការ "កម្មវិធីបណ្តាញព័ត៌មាននិងសកម្មភាពត្រួតពិនិត្យគ្រប់គ្រងការប្រើប្រាស់គ្រឿងញៀនក្នុងតំបន់" (**IOGT-RIANDAC**) នៅកម្ពុជាឆ្នាំទី១ ដំណាក់កាលទី២ (២០០៧-២០០៩) ។ ក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារនេះ តាមការស្នើសុំរបស់អង្គការ**IOGT-RIANDAC** អគ្គលេខាធិការដ្ឋាន អជបគញ បានជូនប័ណ្ណសរសើរចំនួន៨ ដល់ស្រុកកណ្តាលស្ទឹង ឃុំគោកត្រប់ វិទ្យាល័យ **ហ៊ុន សែន** កំពង់កន្ទួត វិទ្យាល័យ **ហ៊ុន សែន** ជម្ពូវ័ន វិទ្យាល័យសន្ធរម៉ុក វិទ្យាល័យបឹងត្របែក វិទ្យាល័យព្រះយុគន្ធរ និងវិទ្យាល័យសាមគ្គី **ជា ស៊ីម** ដែលមានស្នាដៃក្នុងការអនុវត្តន៍កម្មវិធីនៃគំរោង ។

ដោយឡែក សមាគមយុវជនខ្មែរ ដែលជាដៃគូរបស់អង្គការ **IOGT-RIANDAC** ក៏បានបន្តការរៀបចំចងក្រងជាក្លឹបយុវវ័យ ដើម្បីដំណើរការបណ្តុះបណ្តាលលើការងារអប់រំបង្ការបញ្ហាគ្រឿងញៀននៅតាមវិទ្យាល័យ អនុវិទ្យាល័យ និង សាលាបឋមសិក្សាចំនួន១៤ នៅក្រុងភ្នំពេញ ខេត្តសៀមរាប បាត់ដំបង បន្ទាយមានជ័យ ប៉ៃលិន និង ខេត្តកណ្តាល ។

-សហការជាមួយគំរោង**AusAID**របស់អូស្ត្រាលី ក្នុងការពិនិត្យនិងវាយតម្លៃលើសេចក្តីព្រាងកម្មវិធីគំរោងសំរាប់តំបន់អាស៊ី **ស្តីពីបញ្ហាមេរោគអេដស៍/ជម្ងឺអេដស៍ដែលពាក់ព័ន្ធនឹងការប្រើបំពានគ្រឿងញៀន** (គំរោង**HAARP**) ដែលមានវិសាលភាពអនុវត្តនៅក្នុងប្រទេសមហាអនុតំបន់ទន្លេមេគង្គ ក្នុងគោលបំណងលើកកំពស់ប្រសិទ្ធិភាពការងារពាក់ព័ន្ធនឹងដំណោះស្រាយ នៃបញ្ហាគ្រឿងញៀន/អេដស៍នៅកម្ពុជា ។

ទន្ទឹមនោះ ដោយបានការគាំទ្រពីក្រសួង-ស្ថាប័នរាជរដ្ឋាភិបាល បណ្ដាស្ថានីយ៍វិទ្យុ-ទូរទស្សន៍ជាតិនិងឯកជន អគ្គលេខាធិការដ្ឋាន អជបគញ បានសហការជាមួយកម្មវិធីនានារបស់អង្គការមិនមែនរដ្ឋាភិបាលក៏ដូចកម្មវិធីនានារបស់អង្គការជាតិនិងអន្តរជាតិក្នុងការផ្ដល់នូវបទសម្ភាសន៍, កម្មវិធីសំណួរចម្លើយតាមកម្មវិធីប្រចាំសប្ដាហ៍ដែលបានគ្រោងទុក ដើម្បីលើកកំពស់ការយល់ដឹងអំពីគ្រឿងញៀន ។

ដើម្បីពង្រឹងសមត្ថភាពនិងប្រសិទ្ធភាពការងារអប់រំផ្សព្វផ្សាយអប់រំ អគ្គលេខាធិការដ្ឋាន បានរៀបចំក្រុមការងារអន្តរក្រសួងមួយ សំរាប់ផ្ដល់កិច្ចសម្ភាសន៍នៅស្ថានីយ៍វិទ្យុនិងទូរទស្សន៍ ដើម្បីលើកកំពស់ការយល់ដឹងជាសាធារណះអំពី :

-ស្ថានភាពគ្រឿងញៀននៅកម្ពុជា ។

-ច្បាប់ស្ដីពី វិសោធនកម្មច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ។

-គោលនយោបាយនិងយុទ្ធសាស្ត្រជាតិក្នុងការត្រួតពិនិត្យគ្រឿងញៀន របស់រដ្ឋាភិបាលនិងអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

-ការយល់ដឹងពីឥទ្ធិពល និង គ្រោះថ្នាក់ចំពោះសុខភាពអ្នកប្រើប្រាស់គ្រឿងញៀន ។

-ការបង្ការទប់ស្កាត់ការឆ្លងរីករាលដាលនៃមេរោគអេដស៍/ជម្ងឺអេដស៍ ដែលបណ្ដាលមកពីការប្រើបំពានគ្រឿងញៀន ។

-ការព្យាបាល ស្ដារនីតិសម្បទា និងការធ្វើសមាហរណកម្មអ្នកញៀនគ្រឿងញៀន ។

## ២.២-ការងារទិន្នន័យព័ត៌មានគ្រឿងញៀន

-តាមរយៈគំរោងទ្វេភាគី(គំរោង **J 11 . UNODC**) ស្ដីពីការកែទម្រង់ស្ថាប័ន និងការពង្រឹងសមត្ថភាពដើម្បីត្រួតពិនិត្យនិងបញ្ចូលការបង្ការការប្រើបំពានគ្រឿងញៀននៅកម្ពុជា បានធ្វើការផ្សព្វផ្សាយនូវរបាយការណ៍ឆ្នាំ២០០៧ ស្ដីពីទិន្នន័យគ្រឿងញៀនខុសច្បាប់និងប្រព័ន្ធតាមដានជាប្រចាំនៅក្នុងប្រទេសកម្ពុជា នៅសណ្ឋាគារកាំបូឌីយ៉ាណាថ្ងៃទី១២/៨/២០០៨ ដែលមានការចូលរួមពី អង្គការជាតិអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្ត-ក្រុង តំណាងស្ថានទូត ... សរុបចំនួន ១២០ នាក់ ។

-តាមរយៈកិច្ចសហការជាមួយ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ សើរស្បែកនិងកាមរោគក្រសួងសុខាភិបាល (**NCHADS**) បាននិងកំពុងបន្តធ្វើការវិភាគរបាយការណ៍ស្ដីពីការអង្កេតពីអត្រានៃមេរោគអេដស៍ក្នុងចំណោមអ្នកប្រើគ្រឿងញៀន នៅតាមមណ្ឌលអប់រំកែប្រែអ្នកញៀនគ្រឿងញៀន ។

**ថ្មីៗនេះ** ក្រុមការងាររបស់មជ្ឈមណ្ឌលព័ត៌មានគ្រឿងញៀន និងក្រុមការងាររបស់ NCHADS បានចុះទៅធ្វើសម្ភាសន៍ជាមួយអតីតៈអ្នកប្រើប្រាស់គ្រឿងញៀន នៅតាមមជ្ឈមណ្ឌលព្យាបាលស្ដារនីតិសម្បទាអ្នកញៀនគ្រឿងញៀនរបស់រដ្ឋ ឯកជននិងអង្គការមិនមែនរដ្ឋាភិបាលចំនួន៨កន្លែង នៅក្នុងខេត្តបាត់ដំបង បន្ទាយមានជ័យ ក្រុងភ្នំពេញ អំពីការប្រើប្រាស់គ្រឿងញៀននិងជម្ងឺកាមរោគ ក្នុងចំណោមយុវជន សរុបបានចំនួន៦៥០នាក់ ដើម្បីមានមូលដ្ឋានក្នុងការធ្វើផែនការអន្តរាគមន៍ ។

-តាមរយៈក្រុមការងារបច្ចេកទេសគ្រឿងញៀន/អេដស៍ (**DHA**) អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និង អាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ បានបង្កើតនិងដាក់អោយប្រើប្រាស់នូវផែនការយុទ្ធសាស្ត្ររយៈពេលបីឆ្នាំ (២០០៨-២០១០) ដើម្បីឆ្លើយតបចំពោះការប្រើបំពានគ្រឿងញៀន និងការឆ្លងរាលដាលនៃមេរោគអេដស៍/ជម្ងឺអេដស៍ ។

-តាមរយៈអង្គការអប់រំវិទ្យាសាស្ត្រនិងវប្បធម៌នៃអង្គការសហប្រជាជាតិ (**the United Nation Educational Scientific Cultural Organization. UNESCO)** ក្រុមការងាររបស់មជ្ឈមណ្ឌលព័ត៌-មានគ្រឿងញៀន នៃអគ្គលេខាធិការដ្ឋាន អជបគញ បានធ្វើការស្ទាបស្ទង់មួយដើម្បីយល់ដឹងកាន់តែច្បាស់ អំពីសេវាកម្មសំរាប់ជនរងគ្រោះដោយការប្រើបំពានគ្រឿងញៀនរបស់អង្គការមិនមែនរដ្ឋាភិបាលចំនួន៥៤ ដែលកំពុងធ្វើសកម្មភាពនៅក្នុងខេត្ត-ក្រុងចំនួន១៤គឺ ក្រុងភ្នំពេញ ក្រុងព្រះសីហនុ ក្រុងប៉ៃលិន ខេត្តកំពង់ស្ពឺ ព្រៃវែង កំពង់ចាម ក្រចេះ កំពង់ធំ សៀមរាប បន្ទាយមានជ័យ បាត់ដំបង ពោធិសាត់ កំពង់ឆ្នាំង និង កោះកុង (ពីខែឧសភាដល់ខែមិថុនាឆ្នាំ២០០៨) ។

-តាមរយៈវិទ្យាស្ថាន **BURNET** របស់អូស្ត្រាលី អគ្គលេខាធិការដ្ឋាន បានចាត់បញ្ជូនមន្ត្រីទៅចូលរួមក្នុងការបណ្តុះបណ្តាលស្តីពីការធ្វើអង្កេតលើការប្រើប្រាស់**ATS** សំរាប់អ្នកប្រើបំពានគ្រឿងញៀននៅក្នុងនិងក្រោមមជ្ឈមណ្ឌលព្យាបាល/ស្តារនីតិសម្បទាអ្នកញៀន នៅក្រុងភ្នំពេញ ខេត្តបាត់ដំបង និង ខេត្តបន្ទាយមានជ័យ ។

### ៣-ការងារព្យាបាល និង ស្តារនីតិសម្បទា

បច្ចុប្បន្ន មានមជ្ឈមណ្ឌលព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនចំនួន ១០ កន្លែង ដែលស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋ រួមមាន :

**-ក្រសួងសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទា** ចំនួន ៤ កន្លែងគឺ មជ្ឈមណ្ឌលយុវនីតិសម្បទាចោមចៅ (ក្រុងភ្នំពេញ), មជ្ឈមណ្ឌលជីវិតថ្មីភ្នំបាក់ (ខេត្តបន្ទាយមានជ័យ), មជ្ឈមណ្ឌលជីវិតថ្មីស្មាច់មានជ័យ (ខេត្តកោះកុង), មជ្ឈមណ្ឌលយុវនីតិសម្បទាជីវិតថ្មីកំពង់កន្ទួត (ខេត្តកណ្តាល) ។

**-ក្រសួងសុខាភិបាល** ចំនួន ១ កន្លែង ជាមជ្ឈមណ្ឌលថ្នាក់ជាតិសំរាប់ព្យាបាលអ្នកជម្ងឺផ្លូវចិត្តនិងអ្នកញៀនគ្រឿងញៀននៅក្នុងមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ។ បន្ថែមពីលើនោះគឺជាកន្លែងព្យាបាលអ្នកញៀនហេរ៉ូអ៊ីនដោយប្រើសារធាតុជំនួស (កម្មវិធីមេដាដូន) ដែលកំពុងរៀបចំដាក់ឱ្យដំណើរការ ។

**-សាលាក្រុងភ្នំពេញ** ចំនួន ១ កន្លែងគឺ មជ្ឈមណ្ឌល"ឱកាសខ្ញុំ" ស្ថិតនៅភូមិសែនសុខ សង្កាត់ឃ្មួញ ខណ្ឌឫស្សីកែវ ។

**-ស្នងការដ្ឋាននគរបាលខេត្តសៀមរាប** ចំនួន ១ កន្លែង ។

**-ស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង** ចំនួន ១ កន្លែង ។

**-បញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តបន្ទាយមានជ័យ** ចំនួន ១ កន្លែង ។

**-បញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តបាត់ដំបង** ចំនួន ១ កន្លែង ។

ក្រៅពីនោះ នៅមានមជ្ឈមណ្ឌលដែលគ្រប់គ្រងដោយឯកជននិងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនទៀត ។

–តាមរយៈគំរោងទ្វេភាគី(គំរោង **AD/CMB/04/H83 . UNODC**) រវាងអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ជាមួយការិយាល័យគ្រឿងញៀននិងឧក្រិដ្ឋកម្មនៃអង្គការសហប្រជាជាតិ ស្តីពីការអភិវឌ្ឍន៍សេវាប្រឹក្សា ព្យាបាល និង ស្តារនីតិសម្បទាផ្អែកលើសហគមន៍សំរាប់ការប្រើបំពានគ្រឿងញៀននៅកម្ពុជា បានធ្វើការបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិ បានចំនួន១៥រូប, គ្រូបង្គោលថ្នាក់ខេត្តក្រុងចំនួន២៤រូប និងមន្រ្តីអនុវត្តន៍(អ្នកបញ្ចូលទិន្នន័យ)ចំនួន២៥២រូប សំរាប់ធ្វើការអង្កេតលើឥរិយាបថអ្នកប្រើបំពានគ្រឿងញៀននិងដៃគូរួមភេទរបស់ពួកគេ នៅក្នុងឃុំចំនួន៦០របស់ខេត្ត–ក្រុងចំនួន១២ ដែលទទួលរងផលប៉ះពាល់គ្រឿងញៀនខ្លាំងក្លាគឺ ភ្នំពេញ ព្រះសីហនុ ប៉ៃលិន បាត់ដំបង បន្ទាយមានជ័យ កំពង់ឆ្នាំង កំពង់ចាម កណ្តាល សៀមរាប ស្ទឹងត្រែង ស្វាយរៀង កោះកុង ។

គំរោងនេះ កំពុងធ្វើការកសាងសមត្ថភាពនៅក្នុងប្រព័ន្ធសេវាសុខភាពនិងសង្គមកិច្ច ដើម្បីរៀបចំផែនការផ្តល់ការព្យាបាលដោយផ្អែកលើសហគមន៍ លើការប្រើបំពានសារធាតុញៀននិងការស្តារនីតិសម្បទា រួមជាមួយការទប់ស្កាត់មេរោគអេដស៍/ជម្ងឺអេដស៍សេវាព្យាបាល និងថែទាំសំរាប់អ្នកប្រើបំពានគ្រឿងញៀននិងដៃគូរួមភេទរបស់គេ ។ សំរាប់ជំហាននៃការដកបទពិសោធន៍លើការកសាងសមត្ថភាពនៅក្នុងប្រព័ន្ធសេវាសុខភាព គំរោង**H83**បានរៀបចំបង្កើតក្រុមប្រឹក្សាយោបល់ ចំពោះអ្នកប្រើប្រាស់គ្រឿងញៀននៅខេត្ត–ក្រុងចំនួន៥គឺ ក្រុងភ្នំពេញ ក្រុងព្រះសីហនុ ខេត្តបាត់ដំបង បន្ទាយមានជ័យ និង សៀមរាប ។

–តាមរយៈ ក្រុមការងារបច្ចេកទេសទទួលបន្ទុកកិច្ចការព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន បាននិងកំពុងបន្តការស្រាវជ្រាវរកវិធីសាស្រ្តដ៏មានប្រសិទ្ធិភាពក្នុងការព្យាបាលអ្នកញៀនគ្រឿងញៀនប្រភេទ ហេរ៉ូអ៊ីន និង **ATS** ។

–ក្រុមការងារអន្តរក្រសួង(ជាពិសេសក្រសួងសុខាភិបាល) បានតាក់តែងសេចក្តីព្រាងសេចក្តីណែនាំវេជ្ជសាស្រ្តស្តីពីការព្យាបាលបន្តដោយប្រើឱសថមេតាដូន ដែលកំពុងដាក់ជូនក្រសួងយុត្តិធម៌ពិនិត្យបន្ថែមលើទិដ្ឋភាពច្បាប់ និងក្រសួងសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទា ពិនិត្យបន្ថែមលើការងារសង្គមកិច្ចនិងយុវនីតិសម្បទា ។ កម្មវិធីមេតាដូននេះ អគ្គលេខាធិការដ្ឋានក៏បានទទួលការគាំទ្រពីអង្គការសុខភាពពិភពលោក(WHO), អង្គការកម្មវិធីមេរោគអេដស៍/ជម្ងឺអេដស៍នៃអង្គការសហប្រជាជាតិ(UNaids)ប្រចាំនៅកម្ពុជា ដើម្បីរួមចំណែកអនុវត្តន៍សំរាប់តំបន់អាស៊ីនូវគំរោងស្តីពី មេរោគអេដស៍/ជម្ងឺអេដស៍ពាក់ព័ន្ធនឹងការប្រើបំពានគ្រឿងញៀន(គំរោង HAARP)និងការព្យាបាលអ្នកញៀនគ្រឿងញៀនដោយប្រើឱសថជំនួស(កម្មវិធីមេតាដូន) ។

ដោយឡែក ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិរបស់ប្រទេសអូស្រ្តាលី(AusAid)ប្រចាំក្រុងបាងកកបានយកចិត្តទុកដាក់ជួយដល់អគ្គលេខាធិការដ្ឋាន ដោយបាន :

-បញ្ចប់ការរៀបចំគោលនយោបាយជាតិស្តីពីការព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀន កាលពីថ្ងៃទី១៥/៨/២០០៨ ។

-ធ្វើការរៀបចំពង្រាងកម្មវិធីមេតាដូន ។

-សម្របសម្រួលឱ្យដំណើរការបានឆាប់រហ័សលើគំរោងទ្វេភាគី ស្តីពីកម្មវិធីសំរាប់តំបន់អាស៊ីស្តីពីបញ្ហាមេរោគអេដស៍/ជម្ងឺអេដស៍ ។

**៤-នីតិកម្ម និង ផែនការ**

**ក-នីតិកម្ម**

ការងារនេះ អគ្គលេខាធិការដ្ឋាន អជបគញ បាន :

-បន្តការយកចិត្តទុកដាក់សម្របសម្រួលអោយព្រះរាជាណាចក្រកម្ពុជា បានចូលជាសមាជិកនៃពិធីសារឆ្នាំ១៩៧២ដែលពិធីសារនេះបានធ្វើវិសោធនកម្មអនុសញ្ញាទោលស្តីពីគ្រឿងញៀនឆ្នាំ១៩៦១ ។

-តាមរយៈក្រុមការងារអន្តរក្រសួង អគ្គលេខាធិការដ្ឋាន អជបគញ បានធ្វើការពិនិត្យនិងកែសំរួលច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

**ខ-ផែនការ**

អគ្គលេខាធិការដ្ឋាន អជបគញ បាន :

-សហការសំរបសំរួលជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ក្នុងការរៀបចំកម្មវិធីវិនិយោគសាធារណ:(២០០៩-២០១១)សំរាប់កិច្ចប្រជុំពិគ្រោះយោបល់**C-G**ប្រចាំឆ្នាំ ។

-អគ្គលេខាធិការដ្ឋាន ដោយមានកិច្ចសហការល្អជាមួយក្រសួងសមាជិក អជបគញ, ក្រសួងពាក់ព័ន្ធនានា, អង្គការជាតិនិងអន្តរជាតិ, អង្គការមិនមែនរដ្ឋាភិបាល បានបន្តយកចិត្តទុកដាក់អនុវត្តនូវផែនការសកម្មភាពជាតិស្តីពីការត្រួតពិនិត្យគ្រឿងញៀនប្រចាំឆ្នាំ២០០៨សំខាន់លើការអភិវឌ្ឍន៍ធនធានមនុស្សតាមរយៈការបណ្តុះបណ្តាលភាសាអន្តរជាតិ កុំព្យូទ័រ ការបណ្តុះបណ្តាលជំនាញអនុវត្តច្បាប់ និងការងារអប់រំផ្សព្វផ្សាយលើកកំពស់ការយល់ដឹងពីគ្រឿងញៀន សំរេចលទ្ធផលបានប្រមាណ៨៥%នៃផែនការប្រចាំឆ្នាំ២០០៨នេះ ។

ជាមួយនោះ ដើម្បីបន្តអនុវត្តតាមយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី២របស់រាជរដ្ឋាភិបាលអាណត្តិទី៤ អគ្គលេខាធិការ ដ្ឋាន អជបគញ បាន :

-ដាក់បញ្ចូលផែនការយុទ្ធសាស្រ្តស្តីពីការត្រួតពិនិត្យគ្រឿងញៀន របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន(២០០៨-២០១៣) ទៅក្នុងផែនការយុទ្ធសាស្រ្តរបស់ក្រសួងមហាផ្ទៃ ។ ទន្ទឹមនោះ អគ្គលេខាធិការដ្ឋាន អជបគញ បានកសាងផែនការសកម្មភាពជាតិស្តីពីការត្រួតពិនិត្យគ្រឿងញៀនសំរាប់ការអនុវត្តន៍បន្តនាឆ្នាំ២០០៩ ។

**៥-កិច្ចសហប្រតិបត្តិការអន្តរជាតិ**

ឆ្នាំ២០០៨នេះ អគ្គលេខាធិការដ្ឋាន អជបគញ បានយកចិត្តទុកដាក់បន្តលើកិច្ចសហប្រតិបត្តិការអន្តរជាតិ ទាំងក្នុងក្របខណ្ឌទ្វេភាគី ពហុភាគី ជាមួយបណ្ដាប្រទេសជាដៃគូអភិវឌ្ឍន៍នៅក្នុងអនុតំបន់ តំបន់ និង អន្តរជាតិ ដែលរួមមាន :

-កិច្ចប្រជុំប្រចាំឆ្នាំទ្វេភាគី / ត្រីភាគី កម្ពុជា-ឡាវ-វៀតណាម លើកទី៧ ស្ដីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន (ខេត្តសៀមរាប ០៤-០៧/១២/២០០៧) ។

-វគ្គបណ្ដុះបណ្ដាល ស្ដីពីការស៊ើបអង្កេតមន្ទីរពិសោធន៍ផលិតគ្រឿងញៀនលួចលាក់ (សាលាជំនាញអនុវត្តច្បាប់អន្តរជាតិ " **ILEA**" (បាងកក ប្រទេសថៃ ២១-៣១/០១/២០០៨) ។

-សន្និសីទអន្តរជាតិលើកទី១៣ ស្ដីពីបញ្ហាគ្រឿងញៀន "**ADEC-13**" (តូក្យូ ប្រទេសជប៉ុន ថ្ងៃទី ២៩/០១-០១/០២/២០០៨) ។

-កិច្ចប្រជុំគំរោង ស្ដីពីសហគមន៍មូលដ្ឋានក្នុងការអភិវឌ្ឍន៍ដំណាំជំនួសដោយបំបាត់ចោលនូវដំណាំអាភៀន នៅអាស៊ីអាគ្នេយ៍ "គំរោង**H84**" (បាងកក ប្រទេសថៃ ២៧-២៨/៣/២០០៨) ។

-កិច្ចប្រជុំមន្ត្រីទំនាក់ទំនងគំរោង**H15** (ក្រុងវៀងច័ន្ទ២៣-២៤/៥/២០០៨) និងកិច្ចប្រជុំថ្នាក់មន្ត្រីជាន់ខ្ពស់ នៃបណ្ដាប្រទេសជាសមាជិកហត្ថលេខីលើអនុស្សារណៈនៃការយោគយល់គ្នា (**MOU**) ឆ្នាំ ១៩៩៣ ស្ដីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន (ក្រុងវៀងច័ន្ទថ្ងៃទី១១-១៣/៦/២០០៨) ។

**ទន្ទឹមនោះ**

-តាមរយៈ គំរោងស្ដីពីការធ្វើឱ្យប្រសើរឡើងនូវភាពជាដៃគូនៃប្រទេសជាសមាជិក**MOU** ក្នុងតំបន់អាស៊ីបូព៌ា (គំរោង**H15**) និងគំរោងស្ដីពីការកែទម្រង់ស្ថាប័ននិងការពង្រឹងសមត្ថភាព ដើម្បីត្រួតពិនិត្យនិងបញ្ចូលការបង្ការការប្រើបំពានគ្រឿងញៀននៅកម្ពុជា (គំរោង**J11**) របស់ការិយាល័យគ្រឿងញៀននិងឧក្រិដ្ឋកម្ម អ.ស.ប អគ្គលេខាធិការដ្ឋាន អជបគញ បានធ្វើជាម្ចាស់ផ្ទះនៃសិក្ខាសាលា ស្ដីពីការអនុវត្តន៍ជាមូលដ្ឋាននូវអនុសញ្ញារបស់អង្គការសហប្រជាជាតិស្ដីពីគ្រឿងញៀន សំរាប់បណ្ដាប្រទេសនៅក្នុងមហាអនុតំបន់ទន្លេមេគង្គនិងប្រទេសនៅក្នុងសមាគមអាស៊ាន (នៅសណ្ឋាគារសាន់វេភ្នំពេញ ថ្ងៃទី០៧-១០/៤/២០០៨) ។

-សហការនិងសម្របសម្រួលជូនប្រតិភូនៃក្រុមទូរទស្សន៍របស់អង្គការសហប្រជាជាតិ ដើម្បីបំពេញទស្សនកិច្ចនិងថតយកសកម្មភាពសំខាន់ៗ ពាក់ព័ន្ធនឹងការងារត្រួតពិនិត្យគ្រឿងញៀន និងការងារអប់រំព្យាបាលនិងស្ដារនីតិសម្បទាអ្នកញៀនគ្រឿងញៀននៅ មន្ទីរប្រឆាំងគ្រឿងញៀន មជ្ឈមណ្ឌលឱកាសខ្ញុំ និង ការិយាល័យទំនាក់ទំនងព្រំដែនខេត្តស្ទឹងត្រែង (២២-២៤/៤/២០០៨) ។

-កិច្ចប្រជុំមន្ត្រីជាន់ខ្ពស់អាស៊ានស្ដីពីគ្រឿងញៀន (ASOD) លើកទី២៩ (២៤-២៧/៨/២០០៨នៅប្រទេសប្រ៊ុយណេ) ។

**ក្រៅពីកិច្ចប្រជុំប្រចាំឆ្នាំ** អគ្គលេខាធិការដ្ឋាន អជបគញ បានចូលរួមនៅក្នុងយន្តការនៃកិច្ចសហ

ប្រតិបត្តិការអាស៊ាន+ចិន គ្មានគ្រឿងញៀនឆ្នាំ២០១៥(ACCORD) ក៏ដូចជាយន្តការនៃកិច្ចសហប្រតិ-បត្តិការអន្តរជាតិ រួមមាន :

-កិច្ចប្រជុំក្រុមការងារទី១ ស្តីពីការលើកកំពស់ការយល់ដឹងជាសាធារណៈ និងកិច្ចប្រជុំក្រុមទី២ ស្តីពីការកាត់បន្ថយគ្រោះថ្នាក់ របស់គំរោង ACCORD (ហូជីមិញ វៀតណាម ០៨-១២/៧/២០០៨)។

-កិច្ចប្រជុំក្រុមការងារទី៣ ស្តីពីការអនុវត្តន៍ច្បាប់ និងកិច្ចប្រជុំក្រុមការងារទី៤ ស្តីពីការអភិ-វឌ្ឍន៍កែប្រែ របស់គំរោង ACCORD (១៦-១៩/៧/២០០៨ ប្រទេសហ្វីលីពីន) ។

-សន្និសីទអាស៊ាន+កូរ៉េ ស្តីពីបញ្ហាគ្រឿងញៀន(សាធារណរដ្ឋកូរ៉េ២០-២២/០១/២០០៨) ។

-កិច្ចប្រជុំផ្តល់ប្រឹក្សាអាស៊ីលើកទី១ ស្តីពីភាពក្រីក្រ ការប្រើប្រាស់គ្រឿងញៀន និង មេរោគអេដស៍/ជម្ងឺអេដស៍ (ឥណ្ឌា ថ្ងៃទី២៦-៣១/០១/២០០៨) ។

-កិច្ចប្រជុំលើកទី៤ នៃក្រុមសហប្រតិបត្តិការអាស៊ីដើម្បីត្រួតពិនិត្យការបង្វែរសារធាតុគីមីផ្សំ (**ACoG**) និងសន្និសីទលើកទី៤ ស្តីពីសារធាតុគីមីផ្សំសំរាប់ផលិតគ្រឿងញៀន**ATS** "**IFCP**" (តូក្យូ ១២ -១៥/០២/២០០៨) ។

-កិច្ចប្រជុំ ស្តីពីការធ្វើតេស្តសាកល្បងលើក្បួនសំរាប់បណ្តុះបណ្តាលអំពីការប្រើបំពានគ្រឿងញៀន **ATS** (ក្រាប៊ី ប្រទេសថៃ ២៥-២៨/៣/២០០៨) ។

-សិក្ខាសាលាថ្នាក់តំបន់ ស្តីពីការចូលរួមរបស់ឧស្សាហកម្មគីមីក្នុងការបង្ការការបង្វែរសារ-ធាតុគីមីផ្សំ(កូឡាឡាំពួរ ម៉ាឡេស៊ី ២៥-២៧/៣/២០០៨) ។

-សិក្ខាសាលាបណ្តុះបណ្តាលសំរាប់យុវជនស្តីពីការអភិវឌ្ឍន៍សង្គមនិងការបង្ការការប្រើបំពានគ្រឿងញៀន(២៣-៣១/៣/២០០៨ខេត្តឈាងរ៉ៃប្រទេសថៃ) ។

-សិក្ខាសាលា និង ទស្សនកិច្ចសិក្សាស្វែងយល់ លើការងារព្យាបាល ស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន នៅតាមមជ្ឈមណ្ឌលគំរូ (ក្រុងហូជីមិញ វៀតណាម ២១-២៥/៤/២០០៨) ។

-សិក្ខាសាលា គំរោងគាំទ្រវិទ្យាសាស្ត្រដើម្បីពង្រឹងការត្រួតពិនិត្យគ្រឿងញៀន**ATS** និងសារ-ធាតុគីមីផ្សំ(នៅទីក្រុងបាងកក១២-១៤/១២/២០០៧) ដើម្បីបង្កើតបណ្តាញនិងធ្វើឱ្យប្រសើរឡើងនូវការផ្លាស់ប្តូរបទពិសោធន៍និងព័ត៌មានរវាងបណ្តាមន្ទីរពិសោធន៍តំបន់អាស៊ី អឺរ៉ុប និង អូសេអានី ដោយផ្តោតសំខាន់ទៅលើការបញ្ចូលទិន្នន័យ គុណភាពរបស់ទិន្នន័យ និង និរន្តរភាពរបស់បណ្តាញ ។

-សិក្ខាសាលាបណ្តុះបណ្តាលគ្រូបង្គោល ស្តីពីការធ្វើឱ្យប្រសើរឡើងនូវការព្យាបាលអ្នកប្រើបំពានគ្រឿងញៀន**ATS** (ទីក្រុងហាណូយ វៀតណាម ១៦-២០/៦/២០០៨) ។

-ទស្សនកិច្ចសិក្សា ស្តីពីគំរូល្អៗនៃការងារព្យាបាលអ្នកញៀនគ្រឿងញៀនប្រភេទអំហ្វេតាមីន (ATS) ប្រទេសអូស្ត្រាលី ២១-២៥/៧/២០០៨ ។

-កិច្ចប្រជុំថ្នាក់មន្ត្រីអនុវត្តន៍ច្បាប់កម្ពុជា-ថៃ-ឡាវ(ខេត្តអ៊ូប៊ុនប្រទេសថៃ០៥-០៨/៨/២០០៨)។

-ទស្សនកិច្ចសិក្សាផ្នែកមន្ទីរពិសោធន៍គ្រឿងញៀន នៅវិទ្យាស្ថានបច្ចេកទេស (ទីក្រុងហាណូយ

ប្រទេសវៀតណាម ០៤-០៨/៨/២០០៨) ។

-វគ្គបណ្តុះបណ្តាល ស្តីពីការត្រួតពិនិត្យសារធាតុគីមីផ្សំ (២៥-៣១/៨/២០០៨ ប្រទេសថៃ) ។

-វគ្គបណ្តុះបណ្តាល ស្តីពីការងារអប់រំបង្ការការប្រើបំពានគ្រឿងញៀន (២៦សីហា-២០កញ្ញា ២០០៨ នៅទីក្រុងតូក្យូប្រទេសជប៉ុន) ។

-សិក្ខាសាលាស្តីពីការអនុវត្តច្បាប់ត្រួតពិនិត្យគ្រឿងញៀន (ខេត្តយូណាន់ប្រទេសចិនថ្ងៃទី១៧ ខែកញ្ញាដល់ថ្ងៃទី០១ខែតុលាឆ្នាំ២០០៨) ។

-វេទិកាពិភពលោកលើកទី១ ប្រឆាំងគ្រឿងញៀន (ទីក្រុងស្តុកខុម ប្រទេសស៊ុយអ៊ែត០៨-១០ ខែកញ្ញាឆ្នាំ២០០៨) ។

-កិច្ចប្រជុំលើកទី១៨ ស្តីពីកិច្ចសហប្រតិបត្តិការមន្ត្រីទំនាក់ទំនងអន្តរជាតិប្រឆាំងនឹងគ្រឿងញៀន (**ADLOMICO**) នៅសាធារណរដ្ឋកូរ៉េ ២៤-២៦ខែកញ្ញាឆ្នាំ២០០៨ ។

## III / **ការសន្និដ្ឋាន :**

តាមរយៈលទ្ធផលការងារខាងលើ បានឆ្លុះបញ្ចាំងពីសកម្មភាពជាច្រើនត្រូវបានអនុវត្តតាមផែនការសកម្មភាពឆ្នាំ២០០៨ ។ ជាបន្តបន្ទាប់យើងទទួលបាននូវការគាំទ្រនិងវាយតម្លៃខ្ពស់ពីសំណាក់បណ្តាប្រទេសម្ចាស់ជំនួយ ពីអង្គការសហប្រជាជាតិ និងអង្គការអន្តរជាតិនានា ។

យើងបានបន្តកិច្ចខិតខំប្រឹងប្រែងយ៉ាងសកម្មដើម្បីទប់ស្កាត់ការហូរចូលគ្រឿងញៀន ពីតំបន់ព្រំដែនធ្វើអោយបរិមាណគ្រឿងញៀនដែលរឹបអូសមានការថយចុះបើប្រៀបធៀបរយៈពេលឆ្នាំ២០០៧ ។

លើការងារអប់រំផ្សព្វផ្សាយលើកកំពស់ការយល់ដឹងពីគ្រឿងញៀន យើងបានចលនាឱ្យមានការចូលរួមយ៉ាងសកម្មពីសំណាក់មហាជនរហូតដល់ថ្នាក់មូលដ្ឋាន ។

ដោយឡែក ការងារព្យាបាលស្តារនិតិសម្បទា កាន់តែត្រូវបានពង្រឹងនិងពង្រីក ដោយមានការចូលរួមយ៉ាងសកម្មពីស្ថាប័នរដ្ឋាភិបាល អង្គការជាតិ អន្តរជាតិ អង្គការសង្គមស៊ីវិលនៅក្នុងស្រុក និងអង្គការសាសនា ធ្វើឱ្យកាត់បន្ថយបាននូវការប្រើបំពានគ្រឿងញៀន និង ការរីករាលដាលនូវមេរោគអេដស៍/ជម្ងឺអេដស៍ក្នុងកំរិតគួរកត់សំគាល់ ។

ចំពោះកិច្ចសហប្រតិបត្តិការអន្តរជាតិក៏មានការរីកចំរើនជាងឆ្នាំមុន ដោយយើងបានពង្រឹងនិងពង្រីកភាពជាដៃគូនិងពង្រឹងនិងពង្រីកនូវប្រព័ន្ធទំនាក់ទំនង ទ្វេភាគី ពហុភាគី ជាមួយបណ្តាប្រទេសក្នុងតំបន់ និង អន្តរជាតិ ។

## IV / **ទិសដៅការងារត្រួតពិនិត្យគ្រឿងញៀន :**

យោងផែនការសកម្មភាពឆ្នាំ២០០៩ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន អគ្គលេខាធិការដ្ឋាន អជបគញ នឹងបន្តអនុវត្តតាមយុទ្ធសាស្ត្រទាំង៥ស្តីពីការត្រួតពិនិត្យគ្រឿងញៀនគឺ :

**១-កាត់បន្ថយនិងឈានទៅលុបបំបាត់ទាំងស្រុងនូវតម្រូវការគ្រឿងញៀន ។**

**២-កាត់បន្ថយនិងឈានទៅលុបបំបាត់ទាំងស្រុវនូវការផ្គត់ផ្គង់គ្រឿងញៀន ។**

**៣-ពង្រឹងការអនុវត្តន៍ច្បាប់ត្រួតពិនិត្យគ្រឿងញៀន ។**

**៤-កាត់បន្ថយគ្រោះថ្នាក់ដែលបណ្តាលមកពីការប្រើបំពានគ្រឿងញៀន ។**

**៥-ពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការអន្តរជាតិ ។**

**ចំពោះមុខ** អគ្គលេខាធិការដ្ឋាន អជបគញ នឹងបន្តសហការសម្របសម្រួលជាមួយក្រសួងស្ថាប័នរដ្ឋាភិបាល អង្គការជាតិនិងអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាលដែលពាក់ព័ន្ធដើម្បីអនុវត្តនូវរាល់កិច្ចការដែលនៅសេសសល់ ហើយដែលបានដាក់បញ្ចូលទៅក្នុងផែនការសកម្មភាពឆ្នាំ២០០៨នេះ ក៏ដូចជាគោលការណ៍ណែនាំរបស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ស ខេង** ប្រធាន អជបគញ ដូចតទៅ :

**១-ការពង្រឹងសមត្ថភាពអគ្គលេខាធិការដ្ឋាន អជបគញ**

១.១-បន្តកិច្ចសហការជាមួយអង្គការជាតិ អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល ជាដៃគូគាំទ្រ ដើម្បីពង្រឹង :

សមត្ថភាពមន្ទីរពិសោធន៍គ្រឿងញៀន ។

-សមត្ថភាពមជ្ឈមណ្ឌលព័ត៌មានគ្រឿងញៀន ។

-សមត្ថភាពការងារអនុវត្តច្បាប់ និង ការអប់រំផ្សព្វផ្សាយ ។

-សមត្ថភាពព្យាបាល ស្តារនីតិសម្បទា និង សមាហរណកម្មអ្នកញៀនគ្រឿងញៀន ។

១.២-បន្តចងក្រងទម្រង់នីតិវិធីតាមបទដ្ឋានបច្ចេកទេសដែលមានសុវត្ថិភាពសំរាប់ប្រតិបត្តិការបង្ក្រាបមន្ទីរពិសោធន៍គ្រឿងញៀនលួចលាក់ ។

**២-ការងារអប់រំផ្សព្វផ្សាយ និង បង្ការទប់ស្កាត់ការប្រើបំពានគ្រឿងញៀន**

២.១-បន្តយកចិត្តទុកដាក់ក្នុងការពង្រឹងសមត្ថភាពក្រុមការងារ គ្រឿងញៀន/អេដស៍ (**D/HA**) ។

២.២-ខិតខំពង្រឹងក្រុមការងារប្រមូលទិន្នន័យអ្នកប្រើគ្រឿងញៀននៅតាមខេត្ត-ក្រុង (**PDCC**) ។

២.៣-បន្តកិច្ចសហការជាមួយក្រសួង-ស្ថាប័ន, អង្គការអន្តរជាតិ, អង្គការមិនមែនរដ្ឋាភិបាលដែលពាក់ព័ន្ធ ដើម្បីលើកកំពស់ការយល់ដឹងពីគ្រឿងញៀន/អេដស៍ ។

២.៤-បន្តជំរុញការតាមដានការអនុវត្តន៍កម្មវិធីម្ទូល/ស៊ីរាំង នៅកម្ពុជា ។

២.៥-បន្តសហការនិងជំរុញការអនុវត្តន៍កម្មវិធីលើកកំពស់ការយល់ដឹងជាសាធារណៈអំពីគ្រឿងញៀន នៅតាមគ្រឹះស្ថានសិក្សា, ក្រសួង-ស្ថាប័ន, រោងចក្រ/សហគ្រាស និង សហគមន៍ ។

**៣-ការងារអនុវត្តច្បាប់**

៣.១-បន្តពង្រឹងយុទ្ធនាការលុបបំបាត់ការដាំដុះដំណាំកញ្ឆា ។

៣.២-លើកកំពស់ការយល់ដឹងអំពីច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៣.៣-បន្តពង្រឹងនិងពង្រីកយន្តការបណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់ដោយកុំព្យូទ័រ (CBT) ។

៣.៤-បន្តសហការជាមួយអង្គការJICA អនុវត្តគំរោងស្តីពីការត្រួតពិនិត្យគ្រឿងញៀននៅកម្ពុជា ។

៣.៥-បន្តសហការជាមួយ**UNODC** ក្នុងការអនុវត្តន៍ :

-គំរោងI61 ស្តីពីយន្តការនៃការរួមបញ្ចូលគ្នាដើម្បីធ្វើឱ្យប្រសើរឡើងថែមទៀតសំរាប់ការិយាល័យទំនាក់ទំនងគ្រឿងញៀននៅព្រំដែន ក្នុងតំបន់អាស៊ីបូព៌ា ។

-គំរោង XAP/I 63 ស្តីពីការត្រួតពិនិត្យសារធាតុគីមីផ្សំ ។

៣.៦-ចូលរួមក្នុងប្រព័ន្ធចែករំលែកព័ត៌មានទិន្នន័យសារធាតុគីមីផ្សំ ដែលរៀបចំឡើងដោយនាយកដ្ឋានត្រួតពិនិត្យគ្រឿងញៀននៃក្រសួងសុខាភិបាលជប៉ុន ។

៣.៧-បន្តជំរុញការអនុវត្តន៍គោលការណ៍ប្រៀបសមរភូមិប្រឆាំងបទល្មើសគ្រឿងញៀន ។

៣.៨-ជំរុញអនុវត្តកិច្ចព្រមព្រៀងទ្វេភាគីជាមួយក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនថៃ (**ONCB**) លើកទី៣ ស្តីពីកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់គ្រឿងញៀន ។

៣.៩-បន្តកិច្ចសហប្រតិបត្តិការជាមួយភាគីកូរ៉េ អនុវត្តគំរោងស្តីពី "ការផ្តល់សមត្ថភាពជំនាញត្រួតពិនិត្យគ្រឿងញៀនដល់មន្ត្រីអនុវត្តន៍ច្បាប់នៅបណ្តាប្រទេសក្នុងសមាគមអាស៊ាន" នៅកម្ពុជា ។

**៤-ការងារទិន្នន័យព័ត៌មានគ្រឿងញៀន**

៤.១-បន្តការងារប្រមូលទិន្នន័យព័ត៌មានគ្រឿងញៀននៅគ្រប់ខេត្ត-ក្រុង និង ស្ថាប័នពាក់ព័ន្ធ ។

៤.២-បន្តសហការជាមួយមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជម្ងឺអេដស៍សើរស្បែកនិងកាមរោគ (**NCHADS**) នៃក្រសួងសុខាភិបាល, ក្នុងការធ្វើរបាយការណ៍ស្តីពីលទ្ធផលអង្កេតពីអត្រាអ្នកមានមេរោគអេដស៍ក្នុងចំណោមអ្នកប្រើគ្រឿងញៀន ។

៤.៣-បន្តសហការជាមួយមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ សើរស្បែក និង កាមរោគនៃក្រសួងសុខាភិបាល, អង្គការសុខភាពពិភពលោក (**WHO**), អង្គការកសាង, អង្គការមិត្តសំឡាញ់និងវិទ្យាស្ថាន **Burnet** របស់អូស្ត្រាលីក្នុងការអង្កេតលើឥរិយាបថនៃការប្រើគ្រឿងញៀន**ATS** ។

**៥-ការងារព្យាបាល**

៥.១-បន្តសហការអនុវត្តគំរោង **H83** របស់**UNODC** ស្តីពីការអភិវឌ្ឍន៍លើសេវាប្រឹក្សាព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនផ្អែលើសហគមន៍ជាមូលដ្ឋាន ក្នុងនោះការងារបន្ទាន់គឺការជ្រើសរើសយកឃុំចំនួន២នៃខេត្ត-ក្រុងនីមួយៗក្នុងចំណោមខេត្ត-ក្រុងទាំង១២ដែលទទួលរងផលប៉ះពាល់គ្រឿងញៀនធ្ងន់ធ្ងរ ដើម្បី :

-ផ្តល់ការកសាងសមត្ថភាពនៅក្នុងប្រព័ន្ធសេវាសុខភាពនិងសង្គមកិច្ច ។

-រៀបចំផែនការផ្តល់ការព្យាបាលផ្អែកលើសហគមន៍លើការប្រើបំពានសារធាតុញៀន និងការស្តារនីតិសម្បទា រួមជាមួយការទប់ស្កាត់មេរោគអេដស៍/ជម្ងឺអេដស៍ សេវាព្យាបាលនិងថែទាំសំរាប់អ្នកប្រើបំពានគ្រឿងញៀននិងដៃគូរួមភេទរបស់គេ ។

**៦-នីតិកម្ម**

៦.១-បញ្ចប់ការរៀបចំគោលនយោបាយជាតិស្តីពីការព្យាបាល ស្តារនីតិសម្បទាអ្នកញៀន ។

៦.២-បន្តជំរុញការរៀបចំបណ្តាលិខិតបទដ្ឋាននានា ដែលពាក់ព័ន្ធនឹងការត្រួតពិនិត្យគ្រឿងញៀន ។

៦.៣-បន្តការពិនិត្យនិងកែសំរួល សមាសភាពសមាជិកក្រុមការងារអន្តរក្រសួងនានា ។

**៧-សហប្រតិបត្តិការអន្តរជាតិ**

៧.១-បន្តអនុវត្តអនុស្សារណៈនៃការយោគយល់គ្នា (**MOU**) ទ្វេភាគីកម្ពុជា-ចិន ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន សារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ និងសារធាតុគីមីផ្សំ។

៧.២-បន្តអនុវត្តនូវស្មារតីនៃកិច្ចប្រជុំទ្វេភាគី / ត្រីភាគី កម្ពុជា-វៀតណាម-ឡាវ ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន ។

៧.៣-ត្រៀមទទួលប្រតិភូវៀតណាមមកកម្ពុជា ដើម្បីពិភាក្សាលើលទ្ធភាពផ្តល់មជ្ឈមណ្ឌលស្តារនីតិ-សម្បទាអ្នកញៀនគ្រឿងញៀនដល់កម្ពុជា ។

៧.៤-ត្រៀមលក្ខណៈចូលរួមគ្រប់សកម្មភាពត្រួតពិនិត្យគ្រឿងញៀនក្នុងក្របខណ្ឌទ្វេភាគី ពហុភាគីទាំងនៅក្នុង តំបន់ និង អន្តរជាតិ ។

ក្រៅពីទិសដៅខាងលើ អគ្គលេខាធិការដ្ឋាននឹងត្រៀមអនុវត្តនូវរាល់គោលការណ៍ណែនាំរបស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រធាន អជបគញ ដើម្បីឆ្លើយតបសំណូមពរចាំបាច់របស់រាជរដ្ឋាភិបាល ។

**អគ្គលេខាធិការស្តីទី**

**កៅ_ខុនដារ៉ា**

**<u>ចំលងជូន</u> :**

-ខុទ្ទកាល័យ **សម្តេចនាយករដ្ឋមន្ត្រី**

-ខុទ្ទកាល័យ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.ញ**

-ឯកឧត្តម អនុប្រធានអចិន្ត្រៃយ៍ អ.ជ.ប.គ.ញ

-ក្រសួងសមាជិក អ.ជ.ប.គ.ញ

-ក្រសួងផែនការ

(ដើម្បីជូនជ្រាប)

-អគ្គលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ

-អគ្គលេខាធិការរង អ.ជ.ប.គ.ញ

-គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្ត-ក្រុង

-នាយកដ្ឋានចំណុះអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ

-នាយកដ្ឋានសរុប ទីស្តីការគណៈរដ្ឋមន្ត្រី

(ដើម្បីមុខការ)

-ឯកសារ-កាលប្បវត្តិ